ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០០៩៦៤ ប្រក.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការប្រមូលចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យរដ្ឋបាលខេត្តបាត់ដំបង សហការជាមួយក្រុមហ៊ុន **សយ ប៉ូរ៉ា ឌីវេឡុបម៉ិន ឯ.ក** អនុវត្តការប្រមូលចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង **(អគារសាលាខេត្តបាត់ដំបងចាស់)** ដើម្បីជាគុណប្រយោជន៍ដល់ចរិការបស់រដ្ឋបាលខេត្តបាត់ដំបង។

តម្លៃសំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង រយៈពេលផ្ដល់សេវា និងសុពលភាព ត្រូវបានកំណត់ដូចខាងក្រោម ÷

| ល.រ | បរិយាយប្រភេទសេវា | តម្លៃសំបុត្រ (រៀល) | រយៈពេលផ្ដល់សេវា | សុពលភាព |
|---|---|---|---|---|
| ១ | សម្រាប់ជនជាតិខ្មែរ អាយុក្រោម ១៨ឆ្នាំ | ឥតគិតថ្លៃ | ភ្លាមៗ | ១ថ្ងៃ |
| ២ | សម្រាប់ជនជាតិខ្មែរ អាយុចាប់ពី ១៨ឆ្នាំឡើងទៅ | ១.០០០/ម្នាក់ | ភ្លាមៗ | ១ថ្ងៃ |
| ៣ | សម្រាប់ជនបរទេស អាយុក្រោម ១០ឆ្នាំ | ឥតគិតថ្លៃ | ភ្លាមៗ | ១ថ្ងៃ |
| ៤ | សម្រាប់ជនបរទេស អាយុចាប់ពី ១០ឆ្នាំឡើងទៅ | ១២.០០០/ម្នាក់ | ភ្លាមៗ | ១ថ្ងៃ |
| ៥ | ការថតរូបអាពាហ៍ពិពាហ៍ | ១០០.០០០/គូ | ភ្លាមៗ | ១ថ្ងៃ |
| ៦ | ការចូលថតចម្រៀង ឬ ភាពយន្តខ្មែរ | ៤០០.០០០/ក្រុម | ភ្លាមៗ | ១ថ្ងៃ |
| ៧ | ការចូលថតចម្រៀង ឬ ភាពយន្តបរទេស | ១.០០០.០០០/ក្រុម | ភ្លាមៗ | ១ថ្ងៃ |
| ៨ | សិស្ស ឬ និស្សិត ដែលមានលិខិតធ្វើកម្មសិក្សា | ឥតគិតថ្លៃ | ភ្លាមៗ | ១ថ្ងៃ |
| ៩ | ប្រតិភូខ្មែរ ឬ បរទេស ដែលមានលិខិតអនុញ្ញាតពីខេត្ត | ឥតគិតថ្លៃ | ភ្លាមៗ | ១ថ្ងៃ |

**ប្រការ២ .-**

រដ្ឋបាលខេត្តបាត់ដំបង ត្រូវបិទផ្សាយជាសាធារណៈនូវប្រកាសអន្តរក្រសួងនេះ ជាពិសេសនៅទីតាំងលក់សំបុត្រ។

នៅទីតាំងលក់សំបុត្រ ត្រូវរៀបចំឱ្យមានកន្លែងសម្រាប់ទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាមានការយឺតយ៉ាវជាដើម។

ការិយាល័យប្រជាពលរដ្ឋខេត្តបាត់ដំបង មានភារកិច្ចទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ារបស់អតិថិជន ទៅតាមនីតិវិធីកំណត់។

**ប្រការ៣ .-**

រដ្ឋបាលខេត្តបាត់ដំបង ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការ ដើម្បីទទួលបម្រើសេវាជូនអតិថិជន ឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ប្រការ៤ .-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៥ .-**

រដ្ឋបាលខេត្តបាត់ដំបង ត្រូវគ្រោងចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបងនៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយគ្រោងចំណូលលម្អិតទៅតាមប្រភេទសំបុត្រនីមួយៗ។

នៅពេលអនុវត្តចំណូល រជ្ជទេយ្យករចំណូលនៃរដ្ឋបាលខេត្តបាត់ដំបងត្រូវទទួលខុសត្រូវប្រាក់ពិសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្របង់ចំណូលថវិកាខេត្ត ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៦ .-**

រដ្ឋបាលខេត្តបាត់ដំបង ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ របាយការណ៍ស្តីពីការអនុវត្តចំណូលពីថ្លៃលក់សំបុត្រចូល

ទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង ជាផ្នែកមួយនៃរបាយការណ៍រួមស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលខេត្តបាត់ដំបង។

**ប្រការ៧ .–**

តម្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង ដូចមានចែងក្នុងប្រការ១ ខាងលើ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ៨ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .–**

អគ្គលេខាធិការ អគ្គស្នងការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ